# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្ដីការក្រសួងយុត្តិធម៌
លេខ ២៩៨ ថទ-៩៨

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**សូមជម្រាបមក**

**លោកប្រធានតុលាការកំពូល**
**លោកប្រធានសាលាឧទ្ធរណ៍**
**លោកប្រធានតុលាការខេត្ត-ក្រុង**

**កម្មវត្ថុ:** អំពីការផ្ញើសេចក្ដីចម្លងសាលក្រម និងសាលដីកាព្រហ្មទណ្ឌស្ថាពរមកការិយាល័យបញ្ជីថ្កោលទោស ។
**យោង:** លិខិតលេខ១៣៥២ រប-៩៦ ចុះថ្ងៃទី០២-១២-៩៦ របស់ក្រសួងយុត្តិធម៌ ។

ខ្ញុំសូមជម្រាបថា ក្រសួងយុត្តិធម៌បានផ្ញើលិខិតដូចមានយោងខាងលើទៅលោកប្រធានតុលាការគ្រប់ជាន់ថ្នាក់ឲ្យផ្ញើសេចក្ដីចម្លងសាលក្រម និងសាលដីកាព្រហ្មទណ្ឌស្ថាពរមកការិយាល័យបញ្ជីថ្កោលទោសឲ្យបានទៀងទាត់ ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ១៩៩៧ មក ដោយបញ្ឈប់ធ្វើបញ្ជីសាលក្រម និងសាលដីកាព្រហ្មទណ្ឌស្ថាពរតទៅទៀត ។

ឆ្លើយតបនឹងលិខិតរបស់ក្រសួង តុលាការភាគច្រើនបានផ្ញើសេចក្ដីចម្លងសាលក្រម និងសាលដីកាព្រហ្មទណ្ឌស្ថាពរមកការិយាល័យថ្កោលទោសតាមការកំណត់ ប៉ុន្តែតុលាការខេត្តខ្លះទៀតពុំទាន់បានផ្ញើមកទេ ។ រីឯតុលាការមួយចំនួនតូចទៀត នៅតែបន្តធ្វើបញ្ជីតាមគំរូជាតារាងរបៀបចាស់តែក្រសួងបានបញ្ឈប់លែងឲ្យធ្វើទៅហើយនោះដដែល ។

ខ្ញុំសូមរំលឹកដល់លោកប្រធានថា ចំពោះតុលាការណាដែលពុំទាន់បានអនុវត្តតាមការណែនាំរបស់ក្រសួងនេះទេ សូមលោកប្រធានយកចិត្តទុកដាក់អនុវត្តឲ្យបានហ្មត់ចត់ផ្ញើសេចក្ដីចម្លងសាលក្រមនិងសាលដីកាព្រហ្មទណ្ឌស្ថាពរមកការិយាល័យថ្កោលទោសឲ្យបានទៀងទាត់កុំពន្យាឡើយ គឺសាលក្រមនិងសាលដីកាព្រហ្មទណ្ឌណាចូលជាស្ថាពរហើយត្រូវតែធ្វើសេចក្ដីចម្លងសាលក្រម និងសាលដីកាព្រហ្មទណ្ឌស្ថាពរនោះផ្ញើទៅការិយាល័យថ្កោលទោសភ្លាម ដើម្បីក្រសួងចេញលិខិតថ្កោលទោសឲ្យប្រជាពលរដ្ឋប្រើប្រាស់ឲ្យបានត្រឹមត្រូវនិងមានប្រសិទ្ធិភាពតាមផ្លូវច្បាប់ម្យ៉ាងទៀតដើម្បីជៀសវាងការខ្វះខាតនូវលក្ខណៈសម្បត្តិរបស់សេចក្ដីចម្លងសាលក្រម និងសាលដីកាព្រហ្មទណ្ឌស្ថាពរសម្រាប់ធ្វើលិខិតថ្កោលទោសនេះ សូមលោកប្រធានជួយកំណត់ឲ្យបានច្បាស់លាស់អំពីសាវតាជាតិរបស់ទណ្ឌិត និងទោសដែលត្រូវផ្ដន្ទាលើទណ្ឌិត ។

សាវតាជាតិរបស់ទណ្ឌិត ត្រូវយកចិត្តទុកដាក់បញ្ជាក់ឲ្យបានច្បាស់លាស់គឺ៖

១-នាមត្រកូល និងនាមខ្លួនរបស់ទណ្ឌិត ដែលត្រូវសរសេរឲ្យបានច្បាស់លាស់ជាទីបំផុត

២-សញ្ជាតិ

៣-ភេទ សំណូមពរសុំកុំប្រើពាក្យ( នាង ) នៅពីមុខឈ្មោះទណ្ឌិត បើជានារីភេទ
សូមកំណត់ថា (ភេទស្រី) ដើម្បីជៀសវាងការភន្ត័ច្រឡំ នឹងឈ្មោះទណ្ឌិតដែលមានត្រកូល( នាង )

៤-ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងប្រព្រឹត្តបទល្មើសនិងថ្ងៃ ខែ ឆ្នាំ ចាប់ខ្លួនព្រមទាំងបទល្មើស

៥-ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងកំណើត ឬអាយុ

៦-ឈ្មោះឪពុក និងម្ដាយរបស់ទណ្ឌិត

៧-ឈ្មោះប្រពន្ធឬប្ដីរបស់ទណ្ឌិត (ប្រសិនបើមាន ឬនៅលីវ)

៨-ទីលំនៅបច្ចុប្បន្នមុនពេលចាប់ខ្លួន

ដោយឡែកចំពោះទណ្ឌិតដែលត្រូវតុលាការសម្រេចផ្ដន្ទាទោសលើទណ្ឌិតសូមសរសេរឲ្យបានច្បាស់លាស់ជាទីបំផុតផងដែរ ។

អាស្រ័យដូចបានជម្រាបជូនខាងលើនេះ សូមប្រធានតុលាការជួយចាត់ការកិច្ចការនេះឲ្យល្អប្រសើនិងទៀងទាត់តាមការណែនាំរបស់ក្រសួង ដើម្បីក្រសួងចេញលិខិតចោលទោសឲ្យបានត្រឹមត្រូវនិងមានប្រសិទ្ធិភាពតាមផ្លូវច្បាប់ ។

ឆ្លៀតឱកាសនេះ ក្រសួងសូមសសើរដោយស្មោះចំពោះលោកប្រធានតុលាការដែលបានយកចិត្តទុកដាក់អនុវត្តការងារនេះបានល្អប្រសើរនិងទៀងទាត់តាមការណែនាំរបស់ក្រសួង ។

ធ្វើនៅភ្នំពេញ ថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៩៨

**រដ្ឋមន្ត្រី**

**ចែម ស្គួន**